សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៩២២

ចុះថ្ងៃទី ២៩_១១_០៦

សាលដីកា

លេខ : ៩១ "ខ"

ចុះថ្ងៃទី ១៤_០៧_០៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្នុងនាមប្រជារាស្ត្រខ្មែរ
### សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤-០៧-២០០៩ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- **លោក** [redacted] ជាប្រធានក្រុមប្រឹក្សា
- **លោក** [redacted] ជាចៅក្រមប្រឹក្សា
- **លោក** [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**កញ្ញា** [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៩២២ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ ដែលមាន:

១- **ជនជាប់ចោទឈ្មោះ** [redacted] **យ៉ាំងឡាំ** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិវៀតណាម មុខរបរធ្វើស្រែ កើតនៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ទីលំនៅសព្វ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៤-១២-២០០៥ (ឃុំខ្លួន)។

២- **ជនជាប់ចោទឈ្មោះ** [redacted] **គ្រឿង** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិវៀតណាម មុខរបរនេសាទត្រី កើតនៅភូមិបន្ទះក្តារ ឃុំព្រែកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃ [redacted] អំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៩-០៤-២០០៦ (ឃុំខ្លួន)។

៣- **ជនជាប់ចោទឈ្មោះ** [redacted] **យ៉ាំងទៀង** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិវៀតណាម មុខរបរនេសាទត្រី កើតនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted] (រ) (គេចខ្លួន)។

លោក [redacted] **លន់** ជាមេធាវីការពារជនជាប់ចោទ។

**ត្រូវជាប់ចោទពីបទ:** មនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **ធីហុង** ភេទប្រុស មុខរបរកម្មករ ទីលំនៅសព្វថ្ងៃភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៨២ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] **គ្រឿង** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៥ ន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៤ ម៉ោងប្រហែល ២១យប់ ជនរងគ្រោះឈ្មោះ [redacted] **យ៉ាំងទូ** និងឈ្មោះ [redacted] **យ៉ាំងណា** បើកទូកម៉ាស៊ីនមួយគ្រឿងទៅដេកចាំស៊ិងត្រី នៅចុងកោះស្នេហា លុះដល់ម៉ោងប្រហែល ១យប់ ពេលជនរងគ្រោះទាំងពីរនាក់កំពុងដេកលក់នៅលើទូក មានជនល្មើស៤នាក់ លួចស្រាយទូកបណ្តែតចុះក្រោមចេញពីស៊ិងត្រី ចម្ងាយប្រហែល ២០០ម៉ែត្រ ជនរងគ្រោះទាំងពីរនាក់ភ្ញាក់ឡើង ឃើញជនមិនស្គាល់មុខ ៤នាក់ កំពុងឈរនៅលើទូកតែមួយ ខ្លះកាន់ដំបងធ្វើសកម្មភាព វាយទៅលើជនរងគ្រោះឈ្មោះ [redacted] **យ៉ាំងទូ** បណ្តាលឱ្យធ្លាក់ទឹក គ្នាវាម្នាក់លោតទឹកតាមចាប់អូសជនរងគ្រោះទៅលើគោក ចងស្លាបសេក វាយរហូតដល់សន្លប់ ហើយយកស្កុតបិទមាត់ ចំណែកកុមារីរងគ្រោះឈ្មោះ [redacted] **យ៉ាំងណា** ត្រូវជនល្មើសចង យកស្កុតបិទមាត់ បិទច្រមុះ ស្លាប់នៅលើឆ្នេរខ្សាច់ជិតនោះដែរ។ ចំណែកទូកម៉ាស៊ីនរបស់ជនរងគ្រោះ ជនល្មើសយកទៅបាត់ ក្រោយមករកឃើញនៅជិតកប៉ាល់ ណាកា។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៥ ន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១- ក- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **យ៉ាំងឡាំ** ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការ ១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥។

ខ- ផ្តន្ទាទោសលើឈ្មោះ [redacted] **គ្រឿង** ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការចំនួន ១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៦។

គ- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **យ៉ាំងឡេង** ភេទប្រុស អាយុ ៣៥ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការចំនួន ១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន មកទទួលទោស។

ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រក.មន ១០២០០៤ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០[illegible]

២- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ, កំបាំងមុខជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៨២ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] គ្រឿង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៥ ន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុច ទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍រឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] យ៉ាំងឡាំ ឆ្លើយនៅតុលាការខេត្តកណ្តាល។

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទៀង ឆ្លើយនៅតុលាការខេត្តកណ្តាល។

ជនជាប់ចោទឈ្មោះ [redacted] គ្រឿង ឆ្លើយថាៈ ថ្ងៃកើតហេតុ ខ្លួនបានចុះទូកមែន តែក្មេងនោះខ្លួនមិនបានសម្លាប់ទេ គឺ២នាក់ទៀតជាអ្នកប្រព្រឹត្ត ពីរនាក់ហ្នឹងរករឿងខ្លួន និងគម្រាមខ្លួនរហូត ខ្លួនអត់ហ៊ានជួយទេ ពេលនោះខ្លួនជាអ្នកអុំទូក។ ទូកមិនមែនជារបស់ខ្លួនទេ នៅលើទូកមានគ្នា ៣នាក់ និងជនរងគ្រោះ គឺក្មេងអាយុប្រហែល ១០ឆ្នាំ។ បច្ចុប្បន្នខ្លួនមានផ្ទុកមេរោគអេដស៍ សុំតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។ សំណូមពរ ខ្លួនសូមតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

ដើមបណ្តឹងរដ្ឋប្បវេណី [redacted] ធីហុង ឆ្លើយថាៈ កូនខ្លួនត្រូវពួកគេសម្លាប់មែន ទាល់តែភ្លឺបានខ្លួនដឹង។ សំណូមពរ ខ្លួនសុំដក ពាក្យបណ្តឹង ព្រោះមិនមានលុយធ្វើដំណើរមកសាលាឧទ្ធរណ៍។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] យ៉ាំងឡាំ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ និងចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] គ្រឿង ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦ បានឆ្លើយថា បក្សពួករបស់គេមានឈ្មោះ [redacted] យ៉ាំងឡាំ និង [redacted] យ៉ាំងទៀង បានធ្វើសកម្មភាពប្លន់ ក្មេងប្រុស២នាក់ ម្នាក់ឈ្មោះ ណា និងមួយទៀតឈ្មោះ នួ ដោយជនរងគ្រោះឈ្មោះ ណា បានស្លាប់ដោយជនត្រូវចោទចង ហើយយកស្កុតបិទមាត់ បិទច្រមុះ។ ឃើញថា មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកលើជនត្រូវចោទទាំង៣នាក់ ពីបទ មនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ហើយដូច្នេះ មហាអយ្យការសូមសន្និដ្ឋាន សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ ន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់តុលាការខេត្តកណ្តាល ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

តាមអង្គហេតុ កូនក្តីខ្លួនបានបញ្ជាក់ថា បានទៅយកទូកនោះមែន តែគាត់មិនបានធ្វើឱ្យក្មេងនោះស្លាប់ទេ ហើយក៏គ្មានចេតនាសម្លាប់ក្មេងនោះដែរ ឯម្តាយរបស់ជនរងគ្រោះគាត់មិនបានស្គាល់ថា អ្នកណាសម្លាប់កូន ហើយកូនក្តីខ្លួនមានជម្ងឺអេដស៍។ សុំលោកប្រធានក្រុមប្រឹក្សា មេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទៀង និងឈ្មោះ [redacted] យ៉ាំងឡាំ
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] គ្រឿង
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

**<u>សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:</u>**

១- បណ្តឹងឧទ្ធរណ៍លេខ ៨២ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] គ្រឿង ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះតាមមាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤ បក្សពួកខ្លួនមាន [redacted] យ៉ាំងឡាំ, ង្វៀង យ៉ាំងទៀង និង [redacted] គ្រឿង បានធ្វើសកម្មភាពប្លន់ជនរងគ្រោះឈ្មោះ ទូ និង ណា ដែលកំពុងដេកលក់នៅលើទូកចាំត្រី ពេលនោះឈ្មោះ [redacted] យ៉ាំងឡាំ និងឈ្មោះ [redacted] យ៉ាំងទៀង ចូលទៅស្រាយទូកបណ្តែតចេញ តាមបញ្ជារបស់ឈ្មោះ [redacted] គ្រឿង។ លុះទូកអណ្តែកចេញបានចម្ងាយប្រហែល១០០ម៉ែត្រ ពួកវាអូសទូកចូលច្រាំង រួចចាប់ផ្តើមប្លន់ ដោយឈ្មោះ [redacted] គ្រឿង ចាប់ឈ្មោះ ណា ចងបិទមាត់ ហើយឈ្មោះ [redacted] យ៉ាំងឡាំ ចាប់ជើង ឯ [redacted] យ៉ាំងទៀង ចាប់ឈ្មោះ ទូ បោះចូលទឹក។ ពួកខ្លួនពិតជាបានរួមគ្នាប្លន់ជនរងគ្រោះ បណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយពេលនោះជនជាប់ចោទ [redacted] គ្រឿង យកស្កុតបិទមាត់ បិទច្រមុះ ។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៣៥ ន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកណ្តាល សម្រេច ត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨២ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] គ្រឿង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ ន ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្ត កណ្តាល ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទបន្តទៀត ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណ: ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] [redacted] | [redacted] |

---

...ភ្នំពេញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 18 ខែ 02 ឆ្នាំ២០១4
ក្រឡាបញ្ជី
[redacted]